សំណៅត្រូវបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2020

*ដូចអ្នកបានដឹងហើយថា ការិយាល័យជំរឿនកំពុងផ្លាស់ប្តូរប្រតិបត្តិការរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ 19 (COVID-19)។ គ្រួសារនានានៅតែអាចឆ្លើយតបទៅនឹងការធ្វើជំរឿនឆ្នាំ 2020 ក្នុងអំឡុងពេលនេះបាន!* លោកអ្នកអាចឆ្លើយតបទៅនឹងការធ្វើជំរឿនដោយខ្លួនអ្នកផ្ទាល់ តាមរយៈអនឡាញ ទូរស័ព្ទ ឬប្រៃសណីយ៍ ដោយមិនតម្រូវជួបផ្ទាល់ជាមួយមន្ត្រីធ្វើជំរឿននោះទេ។ កាលបរិច្ឆេទកំណត់សម្រាប់ការឆ្លើយបតត្រូវបានពន្យាពេលពីថ្ងៃទី 31 ខែកក្កដា ទៅថ្ងៃទី 31 ខែតុលា។

- អ្នកអាចឆ្លើយតបតាមអនឡាញនៅលើគេហទំព័រ www.2020census.gov.
- អ្នកអាចសាកសួរសំណួរឬឆ្លើយតបតាមរយៈទូរស័ព្ទ។ សូមមើលលេខទូរស័ព្ទនៅលើខិត្តបណ្ណព័ត៌មានជំរឿនរបស់យើង។
- ប្រសិនបើ អ្នកមិនបានឆ្លើយតបទៅនឹងការធ្វើជំរឿនទេ ការិយាល័យជំរឿននឹងផ្ញើឱ្យអ្នកនូវបណ្ណប្រៃសណីយ៍ដែលមានលេខអត្តសញ្ញាណសម្គាល់តែមួយគត់របស់អ្នក នូវក្នុងអំឡុងពេលសប្តាហ៍នៃថ្ងៃទី22 ខែកក្កដា។
  - វានឹង**មិន**ភ្ជាប់មកជាមួយនូវកម្រងសំណួរទេ ដូចនេះអ្នកត្រូវចូលទៅកាន់អនឡាញ ឬទូរស័ព្ទទៅការិយាល័យជំរឿន ដើម្បីឆ្លើយតប។
  - ប្រសិនបើ អ្នកបានទទួលកម្រងសំណួរតាមរយៈបណ្ណប្រៃសណីយ៍ពីមុនមក អ្នកនៅតែអាចឆ្លើយតបតាមប្រៃសណីយ៍ដោយប្រើក្រដាសកម្រងសំណួរនោះបាន។ ប៉ុន្តែ ការិយាល័យជំរឿនគ្មានគម្រោងផ្ញើនូវកម្រងសំណួរថ្មីទៅកាន់គ្រួសារ ដែលពុំបានឆ្លើយតបក្នុងរយៈពេលនោះទេ។
- ការិយាល័យជំរឿនបានផ្ញើបណ្ណប្រៃសណីយ៍ពួកនៅរវាងថ្ងៃទី 24 ខែមិថុនា និងថ្ងៃទី 3 ខែកក្កដា ទៅកាន់ប្រអប់សំបុត្រប្រៃសណីយ៍នៅក្នុងសហគមន៍ ដែលជាប្រអប់សំបុត្រប្រៃសណីយ៍តែមួយគត់មានអាសយដ្ឋានអាចផ្ញើទៅបាន។
  - បណ្ណប្រៃសណីយ៍ ជូនដំណឹងគ្រួសារឱ្យបានដឹងថា មន្ត្រីធ្វើជំរឿនអាចនឹងផ្ញើលិខិតអញ្ជើញឱ្យធ្វើជំរឿនក្នុងពេលឆាប់ៗ ឬក៏នឹងមកសម្ភាសពួកគេនៅពេលក្រោយ។ បណ្ណប្រៃសណីយ៍ក៏នឹងផ្តល់ព័ត៌មានអំពីរបៀបឆ្លើយតបទៅនឹងជំរឿន ឆ្នាំ 2020តាមរយៈអនឡាញ ឬទូរស័ព្ទ។ គ្រួសារគួរឆ្លើយតបទៅនឹងជំរឿនឆ្នាំ 2020 ភ្លាមៗ នៅពេលពួកគេបានទទួលលិខិតអញ្ជើញឱ្យធ្វើជំរឿន។
  - គ្រួសារដែលទទួលសំបុត្រប្រៃសណីយ៍នៅប្រអប់សំបុត្រប្រៃសណីយ៍ គួរផ្តល់នូវអាសយដ្ឋានផ្លូវរបស់ពួកគេ (មិនមែនលេខប្រអប់សំបុត្រទេ) នៅពេលឆ្លើយតប ដើម្បីធានាថាការឆ្លើយតបរបស់ពួកគេត្រូវគ្នានឹងទីកន្លែងដែលពួកគេរស់នៅ មិនមែនទីកន្លែងដែលពួកគេទទួលប្រៃសណីយ៍ទេ។ គ្រួសារអាចឆ្លើយតបលើអនឡាញជាភាសាអង់គ្លេស ឬភាសា 12 ផ្សេងទៀត តាមរយៈទូរស័ព្ទ ដោយអត្តសញ្ញាសម្គាល់ជំរឿន ដែលត្រូវបានបញ្ចូលនៅក្នុងកញ្ចប់នោះ ឬដោយបំពេញនិងផ្ញើតាមប្រៃសណីយ៍ត្រឡប់ទៅវិញនូវកម្រងសំណួរដែលបានផ្តល់ឱ្យដល់ពួកគេ។

សូមមើលសន្លឹកព័ត៌មាននៅខាងក្រោម ដើម្បីស្វែងយល់ព័ត៌មានបន្ថែមអំពីរបៀបត្រូវឆ្លើយតប និងរបៀបទទួលបានជំនួយភាសា។

ទាំងនេះគឺជាបច្ចុប្បន្នភាពនៃការផ្លាស់ប្តូរប្រតិបត្តិការរបស់ការិយាល័យជំរឿន៖

- កាលបរិច្ឆេទចុងក្រោយសម្រាប់ការឆ្លើយតប តាមរយៈអនឡាញ ទូរស័ព្ទ ឬផ្ញើប្រៃសណីយ៍នូវសន្លឹកទម្រង់ព័ត៌មានត្រឡប់ទៅវិញ ត្រូវបានពន្យាពេលពីថ្ងៃទី 31 ខែកក្កដា ដល់ថ្ងៃទី 31 ខែតុលា។
- ជនដែលគ្មានផ្ទះស្នាក់នៅ នឹងត្រូវរាប់បញ្ចូលនៅទីកន្លែងដែលពួកគេកំពុងស្នាក់នៅ នាពេលដែលមន្ត្រីធ្វើជំរឿនមកជួបនៅចន្លោះពីថ្ងៃទី 22-24 ខែកញ្ញា។ មន្ត្រីធ្វើជំរឿន នឹងអនុវត្តតាមគោលការណ៍ណែនាំស្តីពីសុខភាពសាធារណៈមូលដ្ឋាន អំពីបរិក្ខារការពារខ្លួន និងគម្លាតសង្គម។
- ចាប់ពីថ្ងៃទី 3-28 ខែកញ្ញា មន្ត្រីធ្វើជំរឿន នឹងចាប់ផ្តើមរាប់ចំនួនប្រជាជន ដែលស្នាក់នៅកន្លែងបោះជំរុំ ឧទ្យាន RV ម៉ារីណា និងសណ្ឋាគារ ប្រសិនបើពួកគេជាធម្មតាមិនរស់នៅទីកន្លែងផ្សេងទៀតទេ។
- ការិយាល័យជំរឿន បានចាប់ផ្តើមធ្វើប្រតិបត្តិការបច្ចុប្បន្នភាពដែលបានរៀបរាប់ នៅថ្ងៃទី 14 ខែមិថុនា។ នៅទីតាំងទាំងនេះ ដោយសារទីតាំងភូមិសាស្ត្រដាច់ស្រយាល មន្ត្រីធ្វើជំរឿនប្រមូលការឆ្លើយតបជំរឿនដោយផ្ទាល់ ជំនួសឱ្យការអញ្ជើញគ្រួសារឆ្លើយតបតាមរយៈអនឡាញ តាមទូរស័ព្ទ ឬប្រៃសណីយ៍។ ប្រតិបត្តិការចាប់ដំណើរការពីថ្ងៃទី 14 ខែមិថុនា ដល់ថ្ងៃទី 29 ខែកក្កដា។
- ការចាប់ផ្តើមតាមដានការមិនឆ្លើយតបជំរឿននាពេលមន្ត្រីធ្វើជំរឿនទៅតាមផ្ទះនីមួយៗ ដើម្បីរាប់ចំនួនគ្រួសារដែលមិនទាន់បានឆ្លើយតប នឹងត្រូវធ្វើការពន្យាពេល។ នៅតំបន់ភាគច្រើន វាត្រូវបានពន្យាពេលទៅថ្ងៃទី 11 ខែសីហា និងត្រូវបញ្ចប់នៅថ្ងៃទី 31 ខែតុលា។
- នៅពាក់កណ្តាលខែកក្កដា ការិយាល័យជំរឿននឹងបើកដំណើរការឡើងវិញនូវការិយាល័យជំរឿននៅប្រាំមួយតំបន់ នៅទូទាំងប្រទេស ហើយនឹងចាប់ផ្តើមការធ្វើការសម្ភាសគ្រួសារ ដែលមិនទាន់បានឆ្លើយតបនឹងជំរឿន ឆ្នាំ2020។
    - នេះគឺជាការចាប់ដំណើរការឆាប់រហ័សមួយ ពីព្រោះប្រទេសភាគច្រើន នឹងមិនតាមដានការមិនឆ្លើយតបដោយផ្ទាល់នោះទេ រហូតដល់ខែសីហា។
    - ការិយាល័យជំរឿនប្រាំមួយតំបន់ ដែលនឹងចាប់ផ្តើមដំណើរការមុន នឹងត្រូវប្រកាសនៅដើម ខែកក្កដា។
    - ការិយាល័យជំរឿនតំបន់បន្ថែមផ្សេងទៀត អាចនឹងត្រូវប្រកាសជាជំហ៊ានបន្ទាប់ នៅចុងខែកក្កដា។
    - **មន្ត្រីធ្វើជំរឿនទាំងអស់ត្រូវបានបណ្តុះបណ្តាលអំពីការអនុវត្តគម្លាតសង្គម។ ពួកគេនឹងដាក់ចេញនូវបរិក្ខារការពារខ្លួន និងអនុវត្តតាមគោលការណ៍ណែនាំក្នុងមូលដ្ឋានសម្រាប់ការប្រើប្រាស់របស់ពួកគេ។**
- <u>*ការសម្ភាសឡើងវិញសម្រាប់ការតាមដានការមិនឆ្លើយតប៖ ក្នុងករណីខ្លះ មន្ត្រីធ្វើជំរឿនទីពីរអាចនឹងមកជួបគ្រួសារដើម្បីធ្វើសម្ភាសខ្លីមួយ ដើម្បីធ្វើប្រាកដថា មន្ត្រីធ្វើជំរឿនគ្រប់រូបបានអនុវត្តតាមការបណ្តុះបណ្តាលរបស់ការិយាល័យជំរឿន និងបំពេញភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ។ ការសម្ភាសឡើងវិញនឹងត្រូវធ្វើឡើងដោយមន្ត្រីធ្វើជំរឿនផ្សេង ក្រៅពីអ្នកដែលបានមកសម្ភាសលើកមុន។ ប្រតិបត្តិការនៃការសម្ភាសឡើងវិញសម្រាប់ការតាមដានការមិនឆ្លើយតប ត្រូវបានកំណត់កម្មវិធីចាប់ពីថ្ងៃទី12 ខែសីហា ដល់ថ្ងៃទី31 ខែតុលា។ មន្ត្រីធ្វើជំរឿនទាំងអស់មានស្លាកអត្តសញ្ញាណសម្គាល់ផ្លូវការ ដែលមានបញ្ជាក់ឈ្មោះ រូបថត ក្រសួងនិម្មិតសញ្ញាពាណិជ្ជកម្មនៃសហរដ្ឋអាមេរិក និងកាលបរិច្ឆេទផុតកំណត់។*</u>

- កម្មវិធីជំនួយកម្រងសំណួរចល័តរបស់ការិយាល័យជំរឿន ត្រូវបាននិងកំពុងធ្វើការកែសម្រួល។ ការិយាល័យជំរឿនសង្ឃឹមថា បុគ្គលិកជំនួយកម្រងសំណួរចល័ត អាចមានលទ្ធភាពចាប់ផ្ដើមផ្ដល់ជំនួយជំរឿនជាបុគ្គលឡើងវិញ នៅសហគមន៍ដែលមានការឆ្លើយតបតិចតួច។ បុគ្គលិកការិយាល័យជំរឿនទាំងអស់ដែលបានចូលរួមក្នុងកម្មវិធីជំនួយកម្រងសំណួរចល័ត នឹងអនុវត្តតាមគោលការណ៍ណែនាំក្នុងមូលដ្ឋាន ជាពិសេសគោរពតាមវិធានបរិក្ខារការពារខ្លួន និងគម្លាតសង្គម។
- ការិយាល័យជំរឿន នឹងបន្តយុទ្ធនាការផ្ដល់ព័ត៌មានរបស់ខ្លួនរហូតដល់ខែតុលា ឆ្នាំ2020។ ការពង្រីកយុទ្ធនាការផ្សព្វផ្សាយនេះ បានទៅដល់ទស្សនិកជនថ្មីៗជាង 33 ភាសា ដែលចំនួននេះធ្វើឱ្យមានការកើនឡើងចំនួនភាសាដែលមិនមែនភាសាអង់គ្លេសសរុបរហូតដល់ 45 ភាសា។ ការពង្រីកភាសាបន្ថែមនេះនឹងមានចំពោះទាំងការផ្សាយពាណិជ្ជកម្មជាអត្ថបទបោះពុម្ពនិងអត្ថបទឌីជីថល ដើម្បីធ្វើជំរឿននៅតំបន់ប្រវត្តិសាស្ត្រ ដែលប្រជាជនពុំត្រូវបានធ្វើជំរឿន។

## ការធ្វើជំរឿនសិស្ស នីស្សិតដែលកំពុងរស់នៅក្នុងបរិវេណសាកលវិទ្យាល័យ

ការិយាល័យជំរឿន នឹងទៅជួបសាកលវិទ្យាល័យនិងមហាវិទ្យាល័យ ដែលមានចំនួនសិស្ស នីស្សិតច្រើនរស់នៅក្នុងបរិវេណនៃសាកលវិទ្យាល័យធំៗ ដើម្បីធ្វើឱ្យប្រាកដថាពួកគេត្រូវបានធ្វើជំរឿនក្នុងទីតាំងត្រឹមត្រូវនៃជំរឿនឆ្នាំ 2020 សូម្បីតែពួកគេបានទៅផ្ទះមុនពេល ដោយសារការបិទសាលា ឬប្ដូរទៅសិក្សាពីចម្ងាយវិញ។

- ការិយាល័យជំរឿន បានស្នើសុំជំនួយពីសិស្ស នីស្សិត ដោយសាកសួរព័ត៌មានមួយចំនួនដែលបានផ្ដល់ជាស្រេចទៅសាកលវិទ្យាល័យ ដោយសិស្ស នីស្សិតដែលស្នាក់នៅក្នុងបរិវេណសាកលវិទ្យាល័យ។
- បុគ្គលិករបស់ការិយាល័យជំរឿន បានចាប់ផ្ដើមទូរស័ព្ទទៅមន្ត្រីសាលា នៅថ្ងៃទី 16 ខែមិថុនា ហើយយ៉ាងហោចណាស់នឹងស្នើសុំនូវឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានមូលដ្ឋាន។ ដោយទទួលបានព័ត៌មាននេះ ការិយាល័យជំរឿនអាចធានាថាសិស្ស នីស្សិតនៃសាកលវិទ្យាល័យនឹងត្រូវបានធ្វើជំរឿនយ៉ាងត្រឹមត្រូវ ដោយរួមទាំងការលុបចោលចម្លើយតបជាន់គ្នាចំពោះជំរឿន ឬការរាប់សិស្ស នីស្សិត (ប្រសិនបើមិនមានកំណត់ត្រាផ្សេងនៃបុគ្គលតែមួយនៅក្នុងទីតាំងផ្សេង)។ ជាមួយនឹងព័ត៌មានដែលការិយាល័យជំរឿនប្រមូលដែលជាព័ត៌មានផ្ទាល់ខ្លួននឹងត្រូវបានការពារដោយច្បាប់។
- មើលលិខិតរបស់ការិយាល័យជំរឿនផ្ញើជូននាយកសាកលវិទ្យាល័យនិងមហាវិទ្យាល័យនៅទីនេះ។

## ការជួលបុគ្គលរបស់ការិយាល័យជំរឿន

ការិយាល័យជំរឿនកំពុងបន្តស្វែងរកនិងជួលមន្ត្រីធ្វើជំរឿន និងបុគ្គលិកបណ្ដោះអាសន្ន។ សូមមើលនៅទីនេះដើម្បីដឹងថាតើខោនធីណាដែលការិយាល័យជំរឿនកំពុងស្វែងរកជួលបុគ្គលិកបម្រើការងារ។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ www.CountUsIn2020.org/covid-19.